ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ : ០៤៣/គលព/១៧

# កំណត់ហេតុ

## សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីការលើកកម្ពស់ ការទទួលបានសិទ្ធិ និងកិច្ចគាំពារកុមារបម្លាស់ទី

## ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧

ឆ្នាំពីរពាន់ដប់ប្រាំពីរ ខែឧសភា ថ្ងៃទីដប់ប្រាំពីរ វេលាម៉ោងប្រាំបី និងសាមសិបនាទីព្រឹក នៅភោជនីយ៍ដ្ឋានទន្លេបាសាក់២ មានបើកសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីការលើកកម្ពស់ការទទួលបានសិទ្ធិ និងកិច្ចគាំពារកុមារបម្លាស់ទី រយៈពេល ១ថ្ងៃ ដែលសហការរៀបចំ និងសម្របសម្រួលដោយ Cambodia ACTs, Terre des Homes, NGOCRC, PLAN, OAK Foundation, ក្រុមប្រឹក្សាជាតិដើម្បីកុមារ និងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ។**

សមាសភាពចូលរួមកិច្ចប្រជុំសរុបចំនួន **៧៩រូប (ស្រី ២១រូប)** រួមមានតំណាងមកពី ក្រសួងមហាផ្ទៃ ក្រសួងការបរទេស ក្រសួងការងារ ក្រសួងកិច្ចការនារី ក្រសួងអប់រំ ក្រសួងសង្គមកិច្ច ក្រសួងយុត្តិធម៌ ក្រសួងព័ត៌មាន ក្រសួងទេសចរណ៍ អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ អគ្គស្នងការដ្ឋាននគរបាលជាតិ Cambodia ACTs, Terre des Homes, NGOCRC, PLAN, OAK Foundation, CLA, SSDM, KNKS, AYRG, CFS, LAC, CCYMCR, CARITAS, IOM, SOC, UNHCR, Mith Samlanh, Ratanak Int, Khmeara, WorldVision, WOMEN, Hagar, ChilrdFund Cambodia, SSO, TDH-NL, KT, CHC, UP Int, IOM, Tdh, CAW, CCASVA, CNCCC និង UN-ACT ។

គោលបំណងរួមនៃសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិគឺ ដើម្បីជាវេទិកាមួយសម្រាប់អ្នកពាក់ព័ន្ធនានាដូចជាកុមារ និងយុវជនវ័យក្មេង និងសង្គមស៊ីវិល ដើម្បីបង្ហាញ និងពិភាក្សាពីទស្សនៈ និងគំនិតទាំងឡាយទាក់ទងនឹងកម្រងឯកសារច្បាប់សកល (Global Compact) ស្តីពីកុមារ និងការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលកម្ពុជា ។

**ជាកិច្ចចាប់ផ្តើម លោក គង់ វិឡា អគ្គលេខធិការ Cambodia ACTs បានឡើងមានមតិស្វាគមន៍គណៈអធិបតី និងភ្ញៀវដែលបានអញ្ជើញចូលរួម រួចបានបទបង្ហាញអំពីសាវតា ដែលនាំឲ្យកើតមានការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនេះឡើង ៖**

ដំបូងគឺផ្តើមចេញពីសេចក្តីថ្លែងការណ៍ក្រុងញូវយ៉កឆ្នាំ២០១៦ ស្តីពីជនភៀសខ្លួន និងជនចំណាកស្រុកដែលជាផែនការរួម ដើម្បីដោះស្រាយបញ្ហាបម្លាស់ទីរបស់ជនភៀសខ្លួន និងជនចំណាកស្រុកដ៏ច្រើនលើសលប់ដែលត្រូវបានអនុម័តជាឯកច្ឆ័នដោយប្រទេសជាសមាជិកចំនួន១៩៣ ដែលក្នុងនោះ អង្គការផ្នែកសិទ្ធិកុមារ និងទីភ្នាក់ងារអង្គការសហប្រជាជាតិជាច្រើនទៀតបានផ្តល់អនុសាសន៍ បង្កើតនូវគោលការណ៍មួយចំនួនសម្រាប់កុមារបម្លាស់ទី និងកុមារដែលទទួលរងផលប៉ះពាល់ដោយការធ្វើចំណាកស្រុក និងបានធ្វើការជាមួយរដ្ឋាភិបាលនៃ

ប្រទេសជាច្រើន ដើម្បីជានាការប្តេជ្ញាចិត្ត និងស្តង់ដារដែលមានស្រាប់ សម្រាប់ការគាំពារកុមារក្នុងបរិបទចំណាកស្រុក ។ គំនិតផ្តួចផ្តើមស្តីពីសិទ្ធិកុមារក្នុងកម្រងឯកសារច្បាប់សកល ដែលមានគណៈកម្មាធិការមួយមានសមាសភាពពីស្ថាប័នជាច្រើន និងធ្វើជាប្រធានដោយ Terre des Hommes Netherlands និងអង្គការសង្គ្រោះកុមារ មានបំណងធានាថាសិទ្ធិរបស់កុមារបម្លាស់ទី និងកុមារដែលទទួលរងផលប៉ះពាល់ដោយសារការធ្វើចំណាកស្រុក ត្រូវបានដាក់បញ្ចូលក្នុងកិច្ចពិភាក្សាពិគ្រោះយោបល់ដែលទាក់ទិននឹងកម្រងឯកសារច្បាប់សកល ស្តីពីជនភៀសខ្លួន និងជនចំណាកស្រុក ។

នៅអាស៊ាន កម្ពុជាជាប្រទេសទី១ ដែលបានឆ្លើយតបចំពោះយុទ្ធនាការនេះ ហើយមុននឹងបើកសិក្ខាសាលាថ្នាក់ជាតិនេះឡើង គឺមានអង្គសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីសិទ្ធិកុមារនៅក្នុងបរិបទសកល បានរៀបចំឡើងនៅខេត្តបាត់ដំបង តាមបែបកុមារមេត្រី ដោយបានជ្រើសរើសកុមារចំនួន ៣៩នាក់ មកពី ១៤រាជធានី-ខេត្ត ដើម្បីពិគ្រោះយោបល់ ដើម្បីយកបេកគំហើញ និងលទ្ធផលមកពិភាក្សាបន្តនៅក្នុងសិក្ខាសាលាថ្នាក់ជាតិនេះ ។

**ជាកិច្ចបន្ត លោកជំទាវ ជូ ប៊ុនអេង បានឡើងធ្វើសុន្ទរកថាស្វាគមន៍ និងបើកអង្គសិក្ខាសាលា ដែលមានខ្លឹមសាររួមដូចខាងក្រោម៖**

សូមអរគុណអ្នកទាំងអស់គ្នាដែលសុទ្ធតែមានការឈឺឆ្អាល និងយកចិត្តទុកដាក់ក្នុងការស្វែងរកដំណោះស្រាយចំពោះបញ្ហាកុមារ ដែលវាជាការទទួលខុសត្រូវរួមរបស់សាកលលោក ជាពិសេសចំពោះបញ្ហាបម្លាស់ទីមិនប្រក្រតីរបស់កុមារ ដែលនាំឲ្យងាយប្រឈមភាពរងគ្រោះ និងខ្វះសិទ្ធិមូលដ្ឋានទាំង៥របស់កុមារ ដែលនាំឲ្យពួកគេក្លាយជាប្រជាជនដែលរដ្ឋមិនទទួលស្គាល់ និងអាចត្រូវបានអូសទាញដោយឧក្រិដ្ឋជន ដែលពួកគេនឹងបង្កផលប៉ះពាល់ដល់សង្គមជាតិវិញនៅថ្ងៃមុខ ។ តើរាជរដ្ឋាភិបាលនឹងធ្វើយ៉ាងដូចម្តេចដើម្បីឲ្យកុមារបម្លាស់ទីទាំងនោះទទួលបាននូវការគាំពារ និងមិនរើសអើង ដែលជាប្រធានបទសំខាន់របស់អង្គសិក្ខាសាលានេះ ដែលតម្រូវឲ្យយើងទាំងអស់គ្នាត្រូវពិភាក្សាពិគ្រោះ ដើម្បីប្រមូលផ្តុំគំនិតយោបល់ធ្វើជាធាតុចូលសម្រាប់យកទៅពិភាក្សានៅថ្នាក់តំបន់ និងថ្នាក់សាកលជាបន្តទៀត ។

**អង្គសិក្ខាសាលាបានប្រព្រឹត្តទៅតាមរបៀបវារៈដូចខាងក្រោម៖**

## ១. បទបង្ហាញ ស្តីពីបរិបទសាកល និងទស្សនៈពីសង្គមស៊ីវិល

*(ដោយលោក Stefan Stoyanov មកពី Terre des Hommes Netherlands)*

Terre des Hommes គឺជាអង្គការអនុវត្តយុទ្ធនាការជាសកល (Destination Unknown Campaign) ដែលនឹងរកផ្លូវចេញគោលការណ៍សម្រាប់ការពារជនភៀសខ្លួន និងកុមារបម្លាស់ទី ដោយធ្វើការប្រមូលផ្តុំនូវគំនិតយោបល់ពីសង្គមស៊ីវិល ដើម្បីផ្តល់គំនិតជូនរដ្ឋាភិបាលដាក់ចូលអង្គការសហប្រជាជាតិ បង្កើតចេញជាកម្រងឯកសារច្បាប់សកលចំនួន២ ទាក់ទងនឹងជនភៀសខ្លួន និងកុមារបម្លាស់ទី ។

លោកបានផ្តល់អនុសាសន៍អំពី គោលការណ៍ទាំង ៩ សម្រាប់ការពារកុមារបម្លាស់ទី និងកុមាររងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ (Protect children on the move and other children affected by migration) ដែលមានដូចខាងក្រោម៖

1. Children first : សកម្មភាពពាក់ព័ន្ធកុមារបម្លាស់ទី និងកុមាររងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ ត្រូវបានចាត់ទុកជាអាទិភាពដំបូងគេ
2. Life to survival and development : កុមារមានសិទ្ធិរស់នៅ និងអភិវឌ្ឍន៍
3. Liberty of movement : កុមារសេរីភាពក្នុងការបម្លាស់ទីក្នុងរដ្ឋរបស់ខ្លួន និងរដ្ឋដ៏ទៃ

4. Detention of child : ដោយសារជាជនអន្តោប្រវេសន៍ ឪពុកម្តាយបានបំពានទៅលើសិទ្ធិរបស់កុមារ និងប្រឆាំងនឹងគោលការណ៍ប្រយោជន៍ល្អបំផុតសម្រាប់កុមារ
5. Not be separated from parents : កុមារមិនត្រូវបំបែកចេញពីឪពុកម្តាយ លុះត្រាទទួលបានអត្ថប្រយោជន៍ល្អបំផុត
6. No child is illegal : កុមារត្រូវបានគាំពាររាល់ទម្រង់រើសអើង
7. All children : ប្រព័ន្ធការពារកុមារត្រូវការពារកុមារបម្លាស់ទី និងកុមាររងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍
8. Migration management measure : វិធានការណ៍គ្រប់គ្រងទេសន្តរប្រវេសន៍មិនត្រូវផ្ទុយនឹងសិទ្ធិរបស់កុមារឡើយ
9. Express their views freely : កុមារអាចសម្តែងចេញនូវទស្សនៈរបស់ខ្លួនដោយសេរី ។

បន្ទាប់មក លោកបានធ្វើបទបង្ហាញអំពី ពង្រាងគោលបំណង (Goals) របស់ Terre des Hommes សម្រាប់ស្នើសុំដាក់បញ្ចូលទៅក្នុង ប្រធានបទទាំង ៦ ចំណុចពាក់ព័ន្ធនឹងកុមារបម្លាស់ទី នៃសេចក្តីថ្លែងការណ៍អង្គការសហប្រជាជាតិ (NYD - New York Declaration) ដែលមានដូចខាងក្រោមៈ

1. Non-Discrimination *(The draft proposes 2 Goals)*
2. Best Interests of the Child *(The draft proposes 1 Goal)*
3. Child Protection *(The draft proposes 1 Goal)*
4. Durable Solutions *(The draft proposes 4 Goals)*
5. Child Immigration Detention *(The draft proposes 1 Goal)*
6. Access to Services : Shelter, Education and Health *(The draft proposes 6 Goals)*

*(កំណត់ចំណាំៈ បរិយាយលម្អិតអំពីប្រធានបទ និងគោលបំណងខាងលើ មាននៅក្នុងឧបសម្ព័ន្ធ)*

** លោកធ្វើបទបង្ហាញអំពីប្រធានបទ និងគោលបំណងនេះ គឺចង់ឲ្យអង្គសិក្ខាសាលាទាំងមូល ចូលរួមធ្វើការពិភាក្សាពិគ្រោះយោបល់អំពីគោលបំណងនីមួយៗ ថាតើត្រូវបន្ថែម ដកចេញ ឬកែសម្រួល ដែលនេះជាគោលបំណងសំខាន់របស់អង្គសិក្ខាសាលា ដើម្បីយកលទ្ធផលទៅពិភាក្សាថ្នាក់តំបន់នៅប្រទេសថៃបន្តទៀត ។

## ២. បទបង្ហាញ ស្តីពីរបកគំហើញរបស់ក្រុមកុមារ បានមកពីសិក្ខាសាលាពិគ្រោះយោបល់នៅខេត្តបាត់ដំបង

*(ដោយក្រុមកុមារ)*

របកគំហើញសំខាន់ៗរបស់ក្រុមកុមារ រួមមានៈ

- ការរើសអើងនៅក្នុងសហគមន៍ថ្មី
- បញ្ហាប្រឈមក្នុងការទទួលសេវាថែទាំ សេវាអប់រំ និងសេវាសុខភាព
- មូលហេតុដែលនាំឲ្យធ្វើចំណាកស្រុក និងបញ្ហាប្រឈម ។

## ៣. បទបង្ហាញ ស្តីពីបទពិសោធន៍ចំណាកស្រុកនៅប្រទេសម៉ាឡេស៊ី

*(ដោយលោកស្រី Irene Xavier មកពី Committee for Asian Women)*

- ប្រទេសម៉ាឡេស៊ីមិនសមទាក់ទាញអ្នកចំណូចថ្មីទេ គឺគ្រាន់តែល្អជាងកម្ពុជាបន្តិចបន្តួច និងនៅទីនោះមានសមាគមន៍អ៊ីស្លាមកម្ពុជា ដែលនាំឲ្យស្ត្រីខ្មែរអ៊ីស្លាមគិតថាល្អ ។

- ៩០% នៃកុមារដែលបានសម្ភាសន៍ បានទៅសាលារៀន ។ ការទៅមិនស្របច្បាប់ នាំឲ្យមានការលំបាកក្នុងការបញ្ជូនកូនទៅសាលារៀន ដូចនេះពួកគាត់បានបញ្ជូនទៅរៀននៅសាលាសមាគមន៍អ៊ីស្លាម ។
- កម្មករខុសច្បាប់ទទួលបានប្រាក់ខែតែ ២ភាគ៣ នៃកម្មករខុសច្បាប់ និងមួយចំនួននៅក្នុងរោងចក្រហូតមិនហ៊ានចេញមកក្រៅ និងមានស្ត្រីខ្លះត្រូវដេកជាមួយថៅកែ ឬសមត្ថកិច្ច ជាការដោះដូរមិនចាប់ខ្លួន ។
- ការដេកហូតលិខិតឆ្លងដែននៅប្រទេសម៉ាឡេស៊ីគឺខុសច្បាប់ តែថៅកែនៅតែធ្វើ ។

៤. បទបង្ហាញ ស្តីពីការស្រាវជ្រាវអំពីភាពងាយរងគ្រោះរបស់កុមារនៅខេត្តបន្ទាយមានជ័យ

*(ដោយលោក Jarrett Davis មកពី up! International)*

- គេយកចិត្តទុកដាក់ចំពោះកុមារីជាងកុមារ៉ា ដោយគិតថាកុមារ៉ាមិនសូវរងគ្រោះដូចកុមារី ។
- មូលហេតុដែលឪពុកម្តាយ និងកូនបម្លាស់ទីទៅទីនោះដោយសារ សុំទាន រកការងារ និងគេចបំណុលជាដើម ។
- កុមារ ៦៣% ជាចំណាកស្រុក និង ៣៧% កើតនៅទៅនោះ ។
- ៤០% នៃកុមារ៉ា និង ២០% នៃកុមារី គឺរស់នៅតាមដងផ្លូវ ។
- កុមារដែលឪពុកម្តាយធ្វើទេសន្តរប្រវេសន៍មាន ២៤% នៅតែឯង ១៨% នៅជាមួយសាច់ញាតិ និង ៩២% រងអំពើហឹង្សា ។
- បញ្ហាប្រឈមគឺ កុមារទទួលរងអំពើហឹង្សា និងការគំរាមកំហែងពីក្រុមបងធំ ហើយកុមារដែលឆ្លងដែនខុសច្បាប់បានទទួលការវាយដំពីតម្រួតថៃ និងចាប់ឃុំខ្លួន ។

៥. ការឆ្លើយតបរបស់មន្ត្រីរាជរដ្ឋាភិបាល ចំពោះសំនួរមួយចំនួនពាក់ព័ន្ធនឹងប្រធានបទ

▪ **ឯកឧត្តម ឧ.ឯក យឹម វិរៈ អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ :**

- រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយជាច្រើនពាក់ព័ន្ធនឹងកុមារ ដែលប្រជាជនទូទៅមិនបានដឹងអស់ ដូចនេះពេលខ្លះពួកគាត់មិនបានដឹងអំពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ។
- រាជរដ្ឋាភិបាលមិនលើកទឹកចិត្តឲ្យធ្វើចំណាកស្រុកទេ តែបើទៅត្រូវទៅដោយស្របច្បាប់ (អាយុ ១៨ឆ្នាំឡើងបានឲ្យទៅ) និងបានបិទច្រករបៀង ដើម្បីទប់ស្កាត់ការចាកចេញដោយខុសច្បាប់ ។
- រាជរដ្ឋាភិបាលកំពុងគិតគូអំពីកុមារដែលធ្វើទេសន្តរប្រវេសន៍តាមឪពុកម្តាយ ដោយបានសហប្រតិបត្តិការជាមួយបណ្តាលប្រទេសជាច្រើនក្នុងក្របខណ្ឌច្បាប់អន្តរជាតិ ទ្វេភាគី និងការផ្តល់សច្ចាប័ន ។
- **អនុសាសន៍សម្រាប់អាស៊ាន** ៖ ចង់បានជំនួយផ្នែកច្បាប់ទៅវិញទៅមក ផ្នែកព្រហ្មទណ្ឌ ការអនុវត្តសន្ធិសញ្ញាបត្យប័ន និងការផ្ទេរទណ្ឌិត ។

▪ **លោកជំទាវ សឿ សុជាតា អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា :**

- ក្រសួងអប់រំមានកិច្ចព្រមព្រៀងជាមួយខេត្តជាប់ព្រំដែន ដើម្បីកុំឲ្យកុមារទៅពីកម្ពុជាមិនមានសាលារៀនគឺឲ្យបញ្ចូលកម្មវិធីរបស់ក្រសួងអប់រំកម្ពុជានៅទីនោះ ដែលមានប្រយោជន៍អាចឲ្យកុមារចេះពីរភាសាផងនិងពេលវិលត្រឡប់មកវិញអាចបន្តការសិក្សាទាន់គេផង ។
- ចំពោះការបង្រៀនគួរក្រៅម៉ោង ក្រសួងមិនអាចគ្រប់គ្រងបានទេ ព្រោះវាជាម៉ោងឯកជនរបស់ពួកគាត់ តែក្រសួងមានក្រមសីលធម៌វិជ្ជាជីវៈ ដែលកំពុងតែជំរុញឲ្យបញ្ហានេះថយចុះ ។
- ចំពោះកាតព្វកិច្ចមាតាបិតាក្នុងការបញ្ជូនកូនឲ្យទៅរៀនចប់កម្រិតមូលដ្ឋាន យើងបានស្ទាប់ស្ទង់ហើយគឺថាបើមានកាតព្វកិច្ចត្រូវតែមានច្បាប់ដាក់ទោស បើឪពុកម្តាយមិនបញ្ជូនកូនទៅរៀន តើយើងត្រូវដាក់ទោសឪពុកម្តាយទេ បើប្រទេសយើងជាប្រទេសកំពុងអភិវឌ្ឍន៍ដូចនេះ ។

បន្ទាប់មក អង្គសិក្ខាសាលាបានបែងចែកជា ៣ ក្រុមពិភាក្សា (ក្រុមមន្ត្រីរាជរដ្ឋាភិបាល ក្រុមសង្គមស៊ីវិល និងក្រុមកុមារ) ដើម្បីធ្វើការពិភាក្សាពិគ្រោះយោបល់ទៅលើ ៧ព្រាងគោលបំណង (Goals) របស់ Terre des Hommes ដែលលោក Stefan Stoyanov បានធ្វើបទបង្ហាញពីខាងលើ ។ បន្ទាប់ពីបានបញ្ចប់កិច្ចពិភាក្សាពិគ្រោះយោបល់ តំណាងក្រុមនីមួយៗបានឡើងធ្វើបទបង្ហាញលទ្ធផលរបស់ខ្លួនដូចខាងក្រោម៖

*(កំណត់ចំណាំ៖ លទ្ធផលរួមនៃកិច្ចពិភាក្សា មាននៅក្នុងឧបសម្ព័ន្ធ)*

▪ <u>ក្រុមមន្ត្រីរាជរដ្ឋាភិបាល</u>

ក្រុមមន្ត្រីរាជរដ្ឋាភិបាលបានធ្វើការកែសម្រួលគោលបំណងក្នុងប្រធានបទទី១ និងទី៤ (ទី២, ៣, ៥ និងទី៦ មិនមានកែសម្រួលទេ)៖




▪ <u>ក្រុមសង្គមស៊ីវិល</u>

ក្រុមសង្គមស៊ីវិលបានចែកជា ៣ក្រុមបន្ត ហើយទទួលបានលទ្ធផលដូចខាងក្រោម៖



▪ក្រុមកុមារ

ក្រុមកុមារសុំបន្ថែមតែ ១ចំណុចខាងក្រោម៖



**ជាទីបញ្ចប់ លោកជំទាវ ជូ ប៊ុនអេង បានផ្តល់អនុសាសន៍ និងមានប្រសាសន៍ថ្លែងអំណរគុណ ជាកិច្ចបិទអង្គសិក្ខាសាលពិគ្រោះយោបល់ថ្នាក់ជាតិ ដែលមានដូចខាងក្រោម៖**

- កិច្ចប្រជុំអង្គការសហប្រជាជាតិគឺ ធ្វើស្របគ្នាពីរ ( Parallel Meeting ) គឺ រដ្ឋាភិបាលជាមួយរដ្ឋាភិបាល និង សង្គមស៊ីវិលជាមួយសង្គមស៊ីវិល ក្នុងពេលតែមួយ និងប្រធានបទតែមួយ ។ ប្រធានបទ និងគោលការណ៍គេបានអនុម័តហើយ តែយើងអាចស្នើសុំបញ្ចូលបន្ថែម ដូចនេះទើបត្រូវប្រជុំពិភាក្សាប្រមូលផ្តុំគំនិតយោបល់សម្រាប់ការស្នើសុំបញ្ចូលបន្ថែមនោះ ។
- សម្រាប់រាជរដ្ឋាភិបាលកម្ពុជា គឺបានមើលឃើញនូវចំណុចចាប់អារម្មណ៍ ក៏ដូចជាបញ្ហាពាក់ព័ន្ធនឹងកុមារទាំងនេះ ដោយបានរៀបចំបង្កើតនូវលិខិតបទដ្ឋាន និងច្បាប់ជាច្រើនពាក់ព័ន្ធនឹងកុមារ ជាពិសេសតែងតែចុះហត្ថលេខាទទួលយកកិច្ចព្រៀមព្រៀងផ្សេងៗដែលពាក់ព័ន្ធនឹងកុមារ ដោយគ្រាន់ការអនុវត្តមិនទាន់មានប្រសិទ្ធិភាពបានគ្រប់តំបន់ផ្សេងៗគ្នា តែបាននិងកំពុងជំរុញបន្ថែម ។ នៅតាមបណ្តាក្រសួងនិងមូលដ្ឋានគឺមានផ្នែកទទួលបន្ទុកកិច្ចការកុមារផងដែរ ហើយលើសពីនេះទៅទៀត រាជរដ្ឋាភិបាលបានបង្កើតឲ្យមាន ក្រុមប្រឹក្សាជាតិដើម្បីកុមារ និង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដែលធ្វើការពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ ។ ទោះជាមានការយកចិត្តទុកដាក់យ៉ាងនេះហើយក្តី ក៏នៅតែមានបញ្ហាប្រឈមមួយចំនួន ដោយកុមារទាំងនោះអាចបម្លាស់ទីដោយ ការស្ម័គ្រចិត្តខ្លួនឯង បញ្ហាគ្រួសារ ការអូសទាញ ការបង្ខិតបង្ខំ ឬទៅតាមគ្រួសារ ដែលទាំងនេះជាបន្ទុករបស់រាជរដ្ឋាភិបាល ដូចនេះហើយបានជារាជរដ្ឋាភិបាលបាននិងកំពុងខិតខំយកចិត្តទុកដាក់ និងស្វែងរកដំណោះស្រាយឲ្យកាន់តែមានប្រសិទ្ធិភាពបន្ថែមទៀត ។
- ចំពោះបញ្ហាចំណាកស្រុក រាជរដ្ឋាភិបាលមិនបានហាមឃាត់ទេ តែត្រូវទៅដោយស្របច្បាប់ និងទទួលបានផលប្រយោជន៍ពេញលេញ កុំទៅហើយពេលត្រឡប់មកវិញក្លាយជាបន្ទុកដល់គ្រួសារ និងសង្គម ។ រាជរដ្ឋាភិបាលក៏បានរៀបចំជាកិច្ចព្រមព្រៀងជាមួយបណ្តាលប្រទេសមួយចំនួន អំពីចំណាកស្រុកនេះផងដែរ គ្រាន់តែមិនទាន់មានប្រសិទ្ធិភាពខ្លាំង ដែលនាំឲ្យចំណាកស្រុកខុសច្បាប់នៅតែមាន ។ ពេលខ្លះទារកនៅក្នុងផ្ទៃត្រូវបានទទួលរងផលប៉ះពាល់ដោយសារម្តាយធ្វើទេសន្តរប្រវេសន៍ ដែលយើងត្រូវរួមគ្នារិះរកវិធីដោះស្រាយ និងការពារពួកគាត់នាពេលនេះ ។
- យើងទើបតែបានមើលឃើញអំពីគោលបំណងទាំងនេះ ហើយបានបញ្ចេញមតិយោបល់ភ្លាមៗដោយមិនមានពេលវេលាច្រើនសម្រាប់គិតពិចារណា ដូចនេះយើងនឹងត្រូវពិភាក្សាជាច្រើនបន្តទៀត ។

- សូមឲ្យ កម្រងឯកសារច្បាប់សកលទាំង២ (Global Compacts) ទទួលបានជោគជ័យ និងធ្លាក់មកវិញឲ្យបណ្តាប្រទេសទាំងអស់អនុវត្តដូចៗគ្នា លែងគិតពីផលប្រយោជន៍រៀងៗខ្លួន ។
- សង្ឃឹមថាយើងទាំងអស់គ្នានឹងបន្តការងារជាមួយគ្នាក្នុងគោលដៅរួម ជាពិសេសក្នុងការការពារកុមារ ។

អង្គសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីការលើកកម្ពស់ការទទួលបានសិទ្ធិ និងកិច្ចគាំពារកុមារបម្លាស់ទី បានបញ្ចប់នៅវេលាម៉ោងដប់ប្រាំពីរល្ងាច ថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសស្និទ្ធស្នាល និងក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ។

ភ្នំពេញ ថ្ងៃទី២៤ខែឧសភាឆ្នាំ២០១៧

**អ្នកធ្វើកំណត់ហេតុ**

គោរពជូន លោកជំទាវ

អនុប្រធានអចិន្ត្រៃយ៍ មេត្តាជ្រាបជាខ្ពង់ខ្ពស់ ។

ភ្នំពេញ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧

**ប្រធានលេខាធិការដ្ឋាន**

ឧត្តមសេនីយ៍ទោ. គង់_ពុទ្ធី

25/05/17

ជូ_ប៊ុនអេង

# 1. NON-DISCRIMINATION

*NYD says*

- We commit to combating xenophobia, racism and discrimination in our societies against refugees and migrants. We will take measures to improve their integration and inclusion, as appropriate, and with particular reference to access to education, health care, justice and language training

*The draft proposes 2 GOALS*

terre des hommes
stops child exploitation



# NON-DISCRIMINATION (2 GOALS)

- Adopt and implement measures to reduce xenophobia, racism and discrimination against refugees and migrants.
- All States receiving significant numbers of migrants take action to improve access for child refugees and migrants to education, health care, justice and language training.

terre des hommes
stops child exploitation

# 2. BEST INTERESTS OF THE CHILD

*NYD says*

- We will protect the human rights and fundamental freedoms of all refugee and migrant children, regardless of their status, and giving primary consideration at all times to the best interests of the child (para. 32).

***The draft proposes 1 GOAL***

- Ensure that decisions concerning all children on the move and other children affected by migration, including those migrating within their country of origin, are governed by the best interests of the child principle. Ensure that accurate and comprehensive disaggregated data are regularly collected to ensure precise measurement of progress.

terre des hommes
stops child exploitation



# 3. CHILD PROTECTION

*NYD says (in the same para. 32 quoted already)*

- We will protect the human rights and fundamental freedoms of all refugee and migrant children, regardless of their status, and giving primary consideration at all times to the best interests of the child. This will apply particularly to unaccompanied children and those separated from their families; we will refer their care to the relevant **national child protection authorities** and other relevant authorities. We will comply with our obligations under the Convention on the Rights of the Child
- The NYD also contains a 'Comprehensive Refugee Response Framework' which outlines the standards for addressing the needs of all refugees and migrants from the initial reception period, along with their changing ongoing needs and culminating in a durable solution.

terre des hommes
stops child exploitation

# CHILD PROTECTION (1 Goal)

- Provide children with adequate social and legal services that constitute child protection in the context of migration, during the migratory journey, at reception and ongoing throughout the process of seeking a durable solution. Child protection in this context refers to, among others: Identification, registration and tracing of family members as appropriate; protection from violence, abuse and exploitation and appropriate recourse when it occurs; access to appropriate legal, consular and social assistance mechanisms; where necessary, appointment of a guardian as soon as practicable; access to information; and provision of basic services that include education, healthcare and psychosocial care. Accurate and comprehensive disaggregated data is collected to ensure precise measurement of progress.



terre des hommes
stops child exploitation

# 4. DURABLE SOLUTIONS

*NYD says*

- We will actively promote durable solutions, particularly in protracted refugee situations...
- *Annex I on "Comprehensive refugee response framework" contains eight more detailed points about durable solutions for child and adult refugees.*
- *The Declaration itself also contains guarantees that exclude certain options that are not regarded as legitimate durable solutions:*
- Any type of return, whether voluntary or otherwise, must be consistent with our obligations under international human rights law and in compliance with the principle of non-*refoulement*. It should also respect the rules of international law and must in addition be conducted in keeping with the best interests of children and with due process



terre des hommes
stops child exploitation

# DURABLE SOLUTIONS (4 Goals)

- Adopt and implement procedures for determining what should happen to unaccompanied or separated children, which explicitly make the best interests of the child a primary consideration in the determination and require the views of a child for whom a durable solution is being sought to be taken into account in accordance with the child's age and maturity
- Agree and implement durable solutions for all unaccompanied or separated children, both refugees and others
- Abandon the practice of issuing residence permits to unaccompanied children that are valid only until they reach the age of 18 and develop durable solutions which are of indefinite validity;
- Agree an internationally-recognized procedure for monitoring returns (of children, whether accompanied or unaccompanied) and for monitoring the subsequent re/integration (of such children) in their countries of origin.

terre des hommes
stops child exploitation



# 5. CHILD IMMIGRATION DETENTION

*NYD*

- [W]e will use it only as a measure of last resort, in the least restrictive setting, for the shortest possible period of time, under conditions that respect their human rights and in a manner that takes into account, as a primary consideration, the best interest of the child, and we will work towards the ending of this practice

*Goal*

- Progressively end the immigration detention of children.

terre des hommes
stops child exploitation

# 6. ACCESS TO SERVICES: SHELTER, EDUCATION AND HEALTH

*NYD*

- We will work to provide for basic health, education and psychosocial development and for the registration of all births on our territories. We are determined to ensure that all children are receiving education within a few months of arrival, and we will prioritize budgetary provision to facilitate this, including support for host countries as required (para 32)
- We stress the importance of addressing the immediate needs of persons who have been exposed to physical or psychological abuse while in transit upon their arrival, without discrimination and without regard to legal or migratory status or means of transportation (para 26)
- + commitments to refugee children

terre des hommes
stops child exploitation



# ACCESS TO SERVICES: SHELTER, EDUCATION AND HEALTH (6 GOALS)

1. Grant refugee and migrant children access to adequate shelter and to education and health services on a par with citizen children up to age 18, regardless of migration status.
2. Put special measures in place to ensure the inclusion of vulnerable children, including girl children, unaccompanied children and children with disabilities in housing and education systems.
3. Collect accurate and comprehensive disaggregated data regularly to ensure precise measurement of progress.

terre des hommes
stops child exploitation

## ACCESS TO SERVICES: SHELTER, EDUCATION AND HEALTH (3 more GOALS)

4. Grant access to health services to all children affected by migration (refugees and others) both in their countries of origin and abroad.
5. Strengthen and build resilient health systems (in line with Sustainable Development Target 3.8) with fundamental goals of achieving universal health coverage and universal access to quality essential health services for all, regardless of their legal status.
6. Make MHPSS part of the "basic health" provision guaranteed to refugees and to other migrant children.

Mental health and psychosocial support services

terre des hommes
stops child exploitation

## ACCESS TO SERVICES: SHELTER, EDUCATION AND HEALTH (3 more GOALS)

4. Grant access to health services to all children affected by migration (refugees and others) both in their countries of origin and abroad.
5. Strengthen and build resilient health systems (in line with Sustainable Development Target 3.8) with fundamental goals of achieving universal health coverage and universal access to quality essential health services for all, regardless of their legal status.
6. Make MHPSS part of the "basic health" provision guaranteed to refugees and to other migrant children.

terre des hommes
stops child exploitation

# Results of the small group discussions
# On
# "The goals for the New York Declaration for Refugee and Migration"

## Topic: 1. Non-Discrimination (2 Goals)

**Goal 1.1:** Adopt and implement measures to reduce xenophobia, racism ~~and~~ discrimination, trafficking and exploitation against refugees and migrants; especially women and children.

**Goal 1.2:** All states receiving significant numbers of migrants and refugees take action to improve access for child refugees and migrants to education, health care, justice and language training with zero discrimination.

## Topic: 2. Best Interests of the Child (1 Goal)

**Goal 2.1:** Ensure that decisions concerning all children on the move and other children affected by migration, including those migrating within their country origin, are governed by the best interest of the children principle. Ensure that accurate and comprehensive disaggregated data are regularly collect to ensure precise measurement of progress.

## Topic: 3. Child Protection

**Goal 3.1:** Provide children with adequate social and legal services that constitute child protection in the context of migration, during the migratory journey, at reception and ongoing throughout the process of seeking a durable solution. Children protection in this context refers to, among others: Identification, registration and tracing of family members as appropriate; protection from violence, abuse and exploitation and appropriate recourse when it occurs; access to appropriate legal, consular and social assistance mechanisms; where necessary, appointment of guardian as soon as practicable; access to information; and provision of basic services that include education, healthcare and psychosocial care and safe reintegration. Accurate and comprehensive disaggregated data is collected to ensure precise measurement of progress.

## Topic 4: Durable Solutions (4 Goals)

**Goal 4.1:** Adopt and implement procedures for determining what should happen to unaccompanied or separated children, which explicitly make the best interests of the child a primary consideration in the determination and require the views of the child for whom a durable solution is being sought to be taken into account in accordance with the child's age and maturity.

**Goal 4.2:** Agree and implement durable solutions for all unaccompanied or separated children, both refugees and others.

**Goal 4.3:** Abandon the practice of issuing residence permits to unaccompanied children that are valid only until they reach the age of 18 and develop durable solutions which are of indefinite validity;

**Goal 4.4:** Agree an internationally-recognized procedure for monitoring returns (of children, whether accompanied or unaccompanied) and for monitoring the subsequent re/integration (of such children) in their countries of origin.

**Topic: 5. Child Immigration Detention (1 Goal)**

**Goal 5.1:** Strengthening the cooperation for retroactive justice/ diversion to pProgressively ending the immigration detention of children for best interests of the children.

**Topic: 6. Access to Services (Shelter, Education and Health) (6 Goals)**

**Goal 6.1:** Grant refugee and migrant children access to adequate shelter (adequate food with nutrition) and to education and health services on a par with citizen children up to age 18, regardless of migration status.

**Goal 6.2:** Put special measures in place to ensure the inclusion of vulnerable children, including girl children, children living with HIV/AID, unaccompanied children and children with disabilities in housing and education systems.

**Goal 6.3:** Set up National mechanism to cCollect accurate and comprehensive disaggregated data regularly to ensure precise measurement of progresses.

**Goal 6.4:** Grant access to health services to all children affected by migration (refugees and others) both in their countries of origin and abroad.

**Goal 6.5:** Strengthen and build resilient health systems (in line with Sustainable Development Target 3.8) with fundamental goals of achieving universal health coverage and universal access to quality essential health services for all, regardless of their legal status.

**Goal 6.6:** Make MHPSS part of the "basic health" provision guaranteed to refugees and to other migrant children

**Goal 6.7: Access to rihts to religious practices and culture, civilizations in accordance with their respective background. (New goal)**